01044402

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 12 / 2014
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចស្តីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការ សម្រាប់ ខៀវ សំផន

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១. អង្គជំនុំជម្រះសាលាដំបូង បានប្រឈមជាមួយនឹងការបដិសេធរបស់មេធាវីដែលតែងតាំងដោយតុលាការសម្រាប់ ខៀវ សំផន មិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ក្នុងខណៈដែលពួកគាត់កំពុងសរសេរសារណាលើបណ្តឹងសាទុក្ខរបស់ខ្លួន នៅក្នុងសំណុំរឿង០០២/០១។ លើសពីនេះទៀត អង្គជំនុំជម្រះបានទទួលសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យតែងតាំងមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ*[1]។

២. ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ខៀវ សំផន ត្រូវបានតំណាងដោយមេធាវីជាតិ គង់ សំអុន និងសហមេធាវីអន្តរជាតិ Arthur VERCKEN និង Anta GUISSÉ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានបង្ហាញនូវទស្សនៈរបស់ខ្លួនជាច្រើនដងរួចមកហើយថា សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ មិនគួរចាប់ផ្តើមឡើយ រហូតដល់មានការវិនិច្ឆ័យជាស្ថាពរលើសំណុំរឿង ០០២/០១ រួមទាំងដំណើរការលើបណ្តឹងសាទុក្ខផងដែរ[2]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធគោលជំហរនេះ[3]។

---

[1] សំណើរបស់សហព្រះរាជអាជ្ញា សុំតែងតាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ ឯកសារ E321 ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤។

[2] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ទំព័រ ១០៧ (ភាសាអង់គ្លេស)។ ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ទំព័រ ៨៥-៨៦ (ភាសាអង់គ្លេស)។ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមស្ថាពរនៃសំណុំរឿង ០០២/០១ មុននឹងចាប់ផ្តើមសំណុំរឿង ០០២/០២ ឯកសារ E301/5/5 ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤។ សំណើរបស់លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ឯកសារ E314/1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤។ សំណើជាបន្ទាន់សុំឲ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឯកសារ E314/5/1 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤ ("សំណើរបស់ ខៀវ សំផន ទាក់ទងនឹងកាលបរិច្ឆេទសវនាការ")។

[3] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរលើសំណុំរឿង ០០២/០១ ឯកសារ E301/5/5/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្តើមសំណុំរឿង ០០២/០២ ឯកសារ E314/5 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើសំណើសុំពន្យារពេល")។ ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឯកសារ E316 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ ខៀវ សំផន សុំឲ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២" ឯកសារ E314/5/3 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤។

៣. ក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ខៀវ សំផន បានជម្រាបជូនអង្គជំនុំជម្រះថា គាត់បានណែនាំមេធាវីការពារក្តីរបស់គាត់មិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នោះទេ។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងនូវហេតុផលមួយចំនួន រួមទាំងកង្វះធនធាន ចំពោះការសម្រេចមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនេះ។ បន្ទាប់មក មេធាវីការពារក្តីបានចាកចេញពីបន្ទប់សវនាការ។

៤. អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ និងបានជូនដំណឹងដល់គ្រប់ភាគីថា អង្គជំនុំជម្រះនឹងដោះស្រាយនូវបញ្ហាធនធាន និងបញ្ហាពាក់ព័ន្ធនានាផងដែរ[4]។ ទោះបីជាមានការបង្គាប់ឱ្យចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការក៏ដោយ ក៏មេធាវីជាតិ និងអន្តរជាតិរបស់ ខៀវ សំផន មិនមានវត្តមាន ឬផ្តល់នូវយុត្តិកម្មត្រឹមត្រូវចំពោះការមិនចូលរួមរបស់ពួកគេឡើយ។ នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់សំណើរបស់ខ្លួនស្នើសុំតែងតាំងក្រុមមេធាវីការពារក្តីដែល *ជាមិត្តរបស់តុលាការ* ដើម្បីធានាដល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយបានអះអាងថា នីតិវិធីនៃការអនុវត្តជាអន្តរជាតិដែលត្រូវបានបង្កើតឡើងយ៉ាងល្អនេះនឹងអនុញ្ញាតឱ្យសវនាការដំណើរការទៅមុខបាន[5]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាមួយ គាំទ្រដល់ការតែងតាំងក្រុមមេធាវីការពារក្តីដែល *ជាមិត្តរបស់តុលាការ* នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤[6]។

៥. នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានព្រមានជាផ្លូវការដល់មេធាវីការពារក្តី ខៀវ សំផន ចំពោះកំហុសឆ្គង អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង និងបានបង្គាប់ ឱ្យគ្រប់ភាគីទាំងអស់ មានវត្តមាននៅក្នុងកិច្ចប្រជុំរៀបចំសវនាការម្តងទៀតនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤[7]

---

[4] សារអេឡិចត្រូនិចរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ទៅភាគីទាំងអស់នៃសំណុំរឿង០០២ ឯកសារ E320.1 ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤។

[5] សំណើរបស់សហព្រះរាជអាជ្ញា សុំតែងតាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ ឯកសារ E321 ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[6] ការគាំទ្ររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅលើ សំណើរបស់សហព្រះរាជអាជ្ញា សុំតែងតាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ ឯកសារ E321/1 ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤។

[7] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន" ឯកសារ E320 ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦ និង ៨។

ដែលនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនោះ ភាគីត្រូវបានផ្តល់ឱកាសឱ្យផ្តល់យោបល់ទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំតែងតាំង*មេធាវីការពារក្តីដែលជាមិត្តរបស់តុលាការ*។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានគាំទ្រសំណើរបស់សហព្រះរាជអាជ្ញា[8] ដោយឡែក ក្រុមមេធាវីការពារក្តីបានអះអាងថា សំណើនេះមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង[9] ឬអនុលោមតាមច្បាប់កម្ពុជា ឬសិទ្ធិរបស់ជនជាប់-ចោទក្នុងការជ្រើសរើសមេធាវីដោយខ្លួនឯងឡើយ[10]។ សហព្រះរាជអាជ្ញា បានឆ្លើយតបថា ដោយសារតែ*មេធាវីការពារក្តីដែលជាមិត្តរបស់តុលាការ* មិនមែនជាមេធាវីសម្រាប់ជនជាប់ចោទនោះទេ ហេតុដូច្នេះមិនមានលក្ខខណ្ឌតម្រូវឱ្យជនជាប់ចោទត្រូវជ្រើសរើសពួកគេនោះឡើយ[11]។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏បានធ្វើសេចក្តីសន្និដ្ឋានបន្ថែមទៀតផងដែរ ទាក់ទងនឹងហេតុផលចំពោះទង្វើរបស់ពួកគេ ដោយបញ្ជាក់ជាថ្មីម្តងទៀតអំពីការមិនយល់ព្រមចូលរួមក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ទៀតឡើយ[12]។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសេចក្តីសន្និដ្ឋានទាំងនេះ និងបានបង្គាប់ឱ្យគ្រប់ភាគីទាំងអស់ចូលរួមនៅក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ដែលចាប់ ផ្តើមនៅថ្ងៃចន្ទ ទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ អង្គជំនុំជម្រះ បានជូនដំណឹងបន្ថែមទៀតដល់មេធាវីការពារក្តី ខៀវ សំផន ឱ្យបានដឹងជាមុនថា អង្គជំនុំជម្រះនឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ប្រសិនបើមេធាវីការពារក្តីខកខានមិនបានគោរពតាមដីកាបង្គាប់ឱ្យចូលរួមនៅក្នុងសវនាការខាងមុខនេះ[13]។

៦. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ មេធាវីការពារក្តី ខៀវ សំផន បានដាក់ "សារណាបញ្ជាក់អំពីគោលជំហរ" ទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ដែលនៅក្នុងសារណានោះ មេធាវីការពារក្តីបានបញ្ជាក់អំពីការមិនយល់ស្របរបស់ខ្លួនជាមួយនឹងសំអាងហេតុ និងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ និងបានបញ្ជាក់ថា គោលជំហររបស់ ខៀវ សំផន នៅរក្សាដដែល ហើយថា

[8] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៤៦ (ភាសាអង់គ្លេស)។

[9] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៥១ (ភាសាអង់គ្លេស)។

[10] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៥២ (ភាសាអង់គ្លេស)។

[11] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៧៧-៧៨ (ភាសាអង់គ្លេស)។

[12] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៧-១៨,៣០-៣៥ (ភាសាអង់គ្លេស)។

[13] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤" ឯកសារ E320/1 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១១។

មេធាវីការពារក្តីនឹងមិនចូលរួមក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឡើយ រហូតដល់ពួកគេដាក់សារណាលើបណ្តឹងសាទុក្ខរួចរាល់[14]។

៧. នៅក្នុងសវនាការថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហមេធាវីជាតិ និងអន្តរជាតិរបស់ ខៀវ សំផន មិនមានវត្តមាននៅក្នុងសវនាការឡើយ។ ជនជាប់ចោទ ខៀវ សំផន ដែលមានវត្តមាននៅពេលនោះ បានបញ្ជាក់ថា គាត់បានណែនាំមេធាវីការពារក្តីរបស់គាត់ឱ្យផ្តង់អារម្មណ៍ទៅលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ និងមិនឱ្យចូលរួមក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឡើយ។ គាត់បានអះអាងទៀតថា ទាំងខ្លួនគាត់ និងមេធាវីការពារក្តីរបស់គាត់ មិនមានធនធានគ្រប់គ្រាន់ដើម្បីធ្វើការទៅលើករណីទាំងពីរនេះ នៅក្នុងពេលតែមួយបានទេ[15]។

៨. អង្គជំនុំជម្រះបានណែនាំដល់ ខៀវ សំផន ថា សិទ្ធិរបស់គាត់ក្នុងការមានមេធាវីតាមការជ្រើសរើសដោយខ្លួនឯង មិនមានលក្ខណៈដាច់ខាតឡើយ ហើយថា អង្គជំនុំជម្រះអាចតែងតាំងមេធាវី ផ្ទុយនឹងបំណងរបស់ជនជាប់ចោទ ប្រសិនបើផលប្រយោជន៍នៃយុត្តិធម៌តម្រូវ។ អង្គជំនុំជម្រះ បានបង្គាប់ឱ្យគាត់ជូនដំណឹងដល់អង្គជំនុំជម្រះនៅត្រឹមវេលាម៉ោង ៤:៣០ នាទី រសៀល ថ្ងៃ អង្គារ ទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អំពីថា តើគាត់បញ្ឈប់ការណែនាំដល់មេធាវីការពារក្តីរបស់គាត់មិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ឬយ៉ាងណា។ អង្គជំនុំជម្រះបានជូនដំណឹងបន្ថែមទៀតដល់គាត់ឱ្យដឹងជាមុនថា អង្គជំនុំជម្រះអាចតែងតាំងមេធាវីរបស់តុលាការ ប្រសិនបើ នៅពេលនេះ ឬនៅពេលណាមួយក្នុងពេលខាងមុខ គាត់ណែនាំដល់មេធាវីការពារក្តីរបស់គាត់មិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២[16]។

៩. ទាក់ទងនឹងការស្នើសុំឱ្យតែងតាំងក្រុមមេធាវីការពារក្តី*ដែលជាមិត្តរបស់តុលាការ* សហព្រះរាជអាជ្ញា បានបញ្ជាក់ថា សំណើរបស់ខ្លួន គឺមិនមែនស្នើឱ្យមានការជំនួសក្រុមមេធាវីការពារក្តីនោះទេ គឺដើម្បីធានា មិនឱ្យជនជាប់ចោទគ្រប់គ្រងទៅលើដំណើរការសវនាការបាន[17]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបថា ដើមបណ្តឹងរដ្ឋប្បវេណីបន្តគាំទ្រសហព្រះរាជអាជ្ញានៅក្នុងសំណើរបស់ពួកគាត់។ ចំណែកឯ ខៀវ សំផន បានបញ្ជាក់អំពីគោលជំហររបស់គាត់ជាថ្មីទៀតថា គោលបំណងរបស់

---

[14] គោលជំហររបស់លោក ខៀវ សំផន បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង E320/1 ឯកសារ E320/1/1 ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (“គោលជំហររបស់ ខៀវ សំផន”) កថាខណ្ឌ ៤៦។

[15] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (ពង្រាង) ទំព័រ ៨-៩ (ភាសាអង់គ្លេស)។

[16] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (ពង្រាង) ទំព័រ ១០-១២, ១៤-១៥ (ភាសាអង់គ្លេស)។

[17] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៦ (ភាសាអង់គ្លេស)។

គាត់ក្នុងការណែនាំមេធាវីរបស់គាត់មិនឱ្យចូលរួមក្នុងសវនាការនោះ គឺមិនមែនដើម្បីរារាំងដល់កិច្ចដំណើរការនីតិវិធីឡើយ[18]។

១០. នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ខៀវ សំផន បានជូនដំណឹងដល់អង្គជំនុំជម្រះ តាមរយៈអង្គភាពគាំពារការការពារក្ដីថា "គាត់បន្តណែនាំដល់មេធាវីការពារក្ដីដែលត្រូវបានតែងតាំងឱ្យគាត់ ឱ្យផ្តោតការយកចិត្តទុកដាក់ និងពេលវេលាទាំងអស់របស់ពួកគេទៅលើការរៀបចំសារណាលើបណ្ដឹងសាទុក្ខរបស់គាត់ក្នុងសំណុំរឿង ០០២/០១ រហូតដល់កាលបរិច្ឆេទផុតកំណត់នៃដាក់សារណាលើបណ្ដឹងសាទុក្ខនេះ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ និងចាប់ផ្ដើមចូលរួមក្នុងកិច្ចដំណើរការសវនាការក្នុងសំណុំរឿង ០០២/០២ ភ្លាមបន្ទាប់ពីពេលនោះទៅ"[19]។

១១. នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងមេធាវីជាតិ និងអន្តរជាតិរបស់ ខៀវ សំផន គឺ លោក គង់ សំអុន លោក Arthur VERCKEN និងលោកស្រី Anta GUISSÉ ឱ្យធ្វើជាមេធាវីចាត់តាំងដោយតុលាការ។ អង្គជំនុំជម្រះបានបង្គាប់ថា មេធាវីតែងតាំងដោយតុលាការត្រូវចូលរួមនៅក្នុងសវនាការលើអង្គសេចក្ដីសំណុំរឿង ០០២/០២ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ហើយអង្គជំនុំជម្រះបានបញ្ជាក់សារជាថ្មីអំពីចេតនារបស់អង្គជំនុំជម្រះ ក្នុងការបន្តនីតិវិធីដូចបានប្រកាសដោយប្រធានអង្គជំនុំជម្រះនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ក្នុងករណីដែលមេធាវីការពារក្ដីខកខានមិនបានចូលរួមដោយមិនមានមូលហេតុត្រឹមត្រូវ[20]។

១២. នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ មេធាវីតែងតាំងដោយតុលាការសម្រាប់ ខៀវ សំផន បានជូនដំណឹងតាមលិខិតមួយជូនមកអង្គជំនុំជម្រះថា ពួកគេនឹងមិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនេះរហូតដល់ពេលខ្លួនបានដាក់សារណាលើបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ចប់រួចរាល់ដែលត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤[21]។ មេធាវីការពារក្ដីបានអះអាងថា ការតែងតាំងថ្មីនេះមានគោលបំណងរារាំងពួកគេមិនឱ្យអនុវត្តតាមការណែនាំរបស់កូនក្ដីពួកគេ ហើយវានឹងជាការចាប់បង្ខំពួកគេឱ្យរំលោភលើក្រមសីលធម៌ ដោយហេតុថា ការតែងតាំងនេះនឹងបង្ខំពួកគេឱ្យបំពេញវិជ្ជាជីវៈផ្ទុយនឹងអ្វីដែលពួកគេចាត់ទុកថាជាផលប្រយោជន៍

---

[18] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៧-៩ (ភាសាអង់គ្លេស)។

[19] សេចក្ដីរាយការណ៍របស់អង្គភាពគាំពារការការពារក្ដី អំពីការពិគ្រោះយោបល់ជាមួយលោក ខៀវ សំផន ឯកសារ E320/1/2 ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[20] សេចក្ដីសម្រេចសំផន ឯកសារ E320/1/2 ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[21] លិខិតស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណា ឯកសារ E320/2/1 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ១-២។ សេចក្ដីសម្រេចស្ដីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន- សាធារណៈ- ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១៤

របស់កូនក្តីពួកគេ[22]។ មេធាវីតែងតាំងដោយតុលាការខកខាន មិនបានចូលរួមនៅក្នុងសវនាការ នាថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ហើយអង្គជំនុំជម្រះ បានបង្ខំចិត្តផ្អាកកិច្ចដំណើរការនីតិវិធីសវនាការរហូតដល់ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥[23]។

## ៣. សំអាងហេតុ

១៣. អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់ ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់ក្នុងរយៈពេល ២ ខែ ចុងក្រោយនេះបានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី។ ទោះបីជាក្រោយការតែងតាំងពួកគេជាមេធាវីរបស់តុលាការក៏ដោយ ក៏មេធាវីការពារក្តីខកខានមិនបានជួយជ្រោមជ្រែងដល់ជនជាប់ចោទនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ដដែល។ អង្គជំនុំជម្រះត្រូវបង្ខំចិត្តចាត់វិធានការនានា ដើម្បីទប់ស្កាត់ការរាំងស្ទះបែបនេះកុំឱ្យកើតមាននាពេលក្រោយទៀត។

១៤. អង្គជំនុំជម្រះមានកាតព្វកិច្ចធ្វើយ៉ាងណាឱ្យការជំនុំជម្រះប្រកបទៅដោយយុត្តិធម៌ និងឆាប់រហ័សដោយត្រូវពិចារណាលើផលប្រយោជន៍នៃយុត្តិធម៌ រួមទាំង ផលប្រយោជន៍របស់គ្រប់ភាគីទាំងអស់ផងដែរ[24]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការពន្យារពេលយូរបន្ថែមទៀតនឹងនាំឱ្យមានផលប៉ះពាល់យ៉ាងច្រើន ក្រោយពីពិចារណាលើអាយុរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទនៅក្នុងរឿងក្តីនេះ។ អាស្រ័យហេតុនេះ វាចាំបាច់ដែល អ.វ.ត.ក ត្រូវប្រើប្រាស់ពេលវេលាដែលមាន ដើម្បីសម្រេចជាស្ថាពរលើបទចោទដែលនៅសេសសល់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន[25]។ ការទុកឱ្យ ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់ ជាអ្នកគ្រប់គ្រងលើការដឹកនាំកិច្ចដំណើរការនីតិវិធីគឺផ្ទុយនឹងកាតព្វកិច្ចមួយនេះ។

---

[22] លិខិតស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណា ឯកសារ E320/2/1 ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ២។

[23] ប្រតិចារិកថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ១, ៣-៤ (ភាសាអង់គ្លេស)។

[24] សេចក្តីសម្រេចស្តីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ ខៀវ សំផន ឯកសារ E320/2 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ កថាខណ្ឌ ១២។

[25] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ឯកសារ E163/5/1/13 ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៥១។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E248/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ៧២។

១៥. ទាំងវិធានផ្ទៃក្នុង ទាំងវិធាននីតិវិធីកម្ពុជា មិនមានចែងដោយផ្ទាល់អំពីស្ថានភាពបច្ចុប្បន្ននេះទេ។ ដូច្នេះ អង្គជំនុំជម្រះ យោងលើវិធាននីតិវិធីដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ[26]។ ការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានាបង្ហាញថា ក្នុងករណីដែលជម្រើសរបស់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទទួលបានមេធាវីការពារក្តី ធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី នៅពេលនោះអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិធ្វើការតែងតាំងមេធាវីឱ្យជួយជ្រោមជ្រែងដល់ជនជាប់ចោទបាន[27]។

១៦. អង្គជំនុំជម្រះបានពិចារណាលើលទ្ធភាព ក្នុងការបង្គាប់ឱ្យមានការជំនួសមេធាវីការពារក្តីភ្លាមៗ សម្រាប់ ខៀវ សំផន។ អង្គជំនុំជម្រះយល់ឃើញថា ការធ្វើដូច្នេះនឹងបណ្តាលឱ្យមានការពន្យារពេលយ៉ាងយូរក្រៃលែងនៅក្នុងដំណាក់កាលនេះ ដោយហេតុថា គ្មានមេធាវីណាមួយដែលយល់ដឹងអំពីសំណុំរឿងដ៏ធំធេងបែបនេះ អាចទទួលការងារជាមេធាវីការពារក្តីភ្លាមៗបាននោះទេ។ ការពន្យារពេលបែបនេះនឹងមិនមែនជាផលប្រយោជន៍នៃយុត្តិធម៌ឡើយ។

---

[26] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយបូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦), មាត្រា ៣៣ ថ្មី។

[27] *សូមមើល ឧ.* រឿងក្តី *Milošević ទល់នឹង រដ្ឋអាជ្ញា* អង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្តី ICTY, IT-02-54-AR73.7 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការចាត់តាំងមេធាវីការពារក្តី ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំរបស់ *Milošević*")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Milošević* អង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តី ICTY, IT-01-54-T ហេតុផលនៃសេចក្តីសម្រេចចាត់តាំងមេធាវីការពារក្តី ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៤។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Šešelj* អង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តី ICTY, IT-03-67-T សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំដីកាបង្គាប់ចាត់តាំងមេធាវីការពារក្តីដើម្បីជួយជ្រោមជ្រែង *Vojislav Šešelj* នៅក្នុងការការពារក្តីរបស់គាត់ ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០០៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* អង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តី ICTY, IT-95-5/18-T សេចក្តីសម្រេចលើការចាត់តាំងមេធាវីការពារក្តី និងដីកាបង្គាប់ឱ្យបន្តកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Norman និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការពិសេសសេរ៉ាឡេអូន SCSL-04-14-T ដីកាសម្រេចលើការចាត់តាំង និងតួនាទីរបស់មេធាវីប្រចាំការ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤។ បទប្បញ្ញត្តិលេខ ៧៦ នៃបទបញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ស្តីពីការចាត់តាំងមេធាវីការពារក្តីដោយអង្គជំនុំជម្រះ)។ *សូមមើល ផងដែរ* រឿងក្តី Croissant ទល់នឹង ប្រទេសអាល្លឺម៉ង់ សាលក្រមតុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្តឹងលេខ ១៣៦១១/៨៨ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩២។ រឿងក្តី X ទល់នឹង ប្រទេសហ្វាំងឡង់ សាលក្រម (អង្គសេចក្តី និងសំណង) តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យបណ្តឹងលេខ ៣៤៨០៦/០៤ ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១២ (សិទ្ធិរបស់ជនជាប់ចោទក្នុងការជ្រើសរើសមេធាវីរបស់ខ្លួនពុំមែនជាសិទ្ធិដាច់ខាត)។

១៧. សហព្រះរាជអាជ្ញាបានស្នើសុំឱ្យតែងតាំងមេធាវីដែល *ជាមិត្តរបស់តុលាការ*ភ្លាមៗ "ដោយត្រូវទទួលខុសត្រូវការពារសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ រហូតដល់ពេលណាមួយ ដែលមេធាវីរបស់ជនជាប់ចោទ វិលត្រឡប់មកចូលរួមនៅក្នុងដំណើរការនីតិវិធីវិញ ឬរហូតដល់ពេលដែលមេធាវីនោះ ត្រូវបានហាមឃាត់លែងឱ្យការពារជនជាប់ចោទដោយសារមូលហេតុប្រព្រឹត្តកំហុសវិជ្ជាជីវៈជាបន្តបន្ទាប់"[28]។ *មេធាវីដែលជាមិត្តរបស់តុលាការនេះ*នឹងមានតួនាទីកម្រិតក្នុងនាមជាជំនួយការដល់តុលាការ និងមិនចាំបាច់ក្នុងការតំណាងឱ្យជនជាប់ចោទនោះទេ[29]។ អង្គ-ជំនុំជម្រះពិចារណាឃើញថា ដើម្បីបំពេញតួនាទីកម្រិតនេះបានប្រកបដោយប្រសិទ្ធភាពក្នុងរយៈពេលមួយជាបណ្តោះអាសន្ន មេធាវីដែល *ជាមិត្តរបស់តុលាការ*នឹងត្រូវការពេលវេលាដើម្បីស្វែងយល់អំពីដំណើរការនៃសំណុំរឿងដ៏ធំធេងបែបនេះ ដែលនឹងនាំឱ្យមានការពន្យារពេលដដែល។ លើសពីនេះទៀត ការតែងតាំងមេធាវីដែល *ជាមិត្តរបស់តុលាការ*សម្រាប់តែរយៈពេលបណ្តោះអាសន្ន រហូតដល់មេធាវីការពារក្តីឈប់រារាំងកិច្ចដំណើរការនីតិវិធីនោះ វាមិនមែនជាការការពារគ្រប់គ្រាន់ចំពោះលទ្ធភាពនៃការរារាំងកិច្ចដំណើរការនីតិវិធីដែលអាចកើតមាននាពេលអនាគតឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះច្រានចោលសំណើសុំរបស់សហព្រះរាជអាជ្ញា ដោយហេតុថា សំណើសុំនេះមិនមានលក្ខណៈសមស្របនៅក្នុងកាលៈទេសៈបច្ចុប្បន្ន ហើយអង្គជំនុំជម្រះចង់បាននូវទម្រង់មួយដែលមានលក្ខណៈប្រសើរជាង ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីអាចដំណើរការទៅមុខបាន។

---

[28] សំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្តី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ ឯកសារ E321 ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ២៣។

[29] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Šešelj* អង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តី ICTY, IT-03-67-T សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំដីកាបង្គាប់ចាត់តាំងមេធាវីការពារក្តីដើម្បីជួយជ្រោមជ្រែង *Vojislav Šešelj* នៅក្នុងការការពារក្តីរបស់គាត់ ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ១៣។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Milošević* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំរបស់*មេធាវីជាមិត្តតុលាការ*ប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការបង្ហាញ និងការរៀបចំការការពារក្តី មតិយោបល់ (យល់ស្រប) ដោយឡែករបស់ចៅក្រម Shahabuddeen រឿងក្តីលេខ IT-02-54-AR73.6 ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៤ កថាខណ្ឌ ១៥ ("មេធាវី*ជាមិត្តតុលាការ*ត្រូវបានកម្រិតមុខនាទីសំខាន់របស់ខ្លួនត្រឹមជាមិត្តរបស់តុលាការតែប៉ុណ្ណោះ ដែលមានមុខនាទីខុសពីមិត្តរបស់ជនជាប់ចោទ")។ សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់*សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ឯកសារ E306/3/1 ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៥ ("*អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* ជាធម្មតា គឺជាអ្នកប្រឹក្សាឯករាជ្យ និងឥតលម្អៀងចំពោះតុលាការ ដែលមានតួនាទីគ្រាន់តែផ្តល់យោបល់ ប៉ុន្តែមិនត្រូវប្រកាន់ជំហរណាមួយនោះទេ")។

១៨. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វាមានលក្ខណៈចាំបាច់ សមស្រប និងជាប្រយោជន៍នៃយុត្តិធម៌ ក្នុងការតែងតាំងមេធាវីប្រចាំការដោយតុលាការ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីនៅក្នុងរឿងក្តីនេះអាច ដំណើរការទៅមុខប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។

១៩. មេធាវីប្រចាំការមានតួនាទីរៀបចំ និងត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលការងារជាមេធាវីការពារក្តីឱ្យ ខៀវ សំផន នៅគ្រប់ពេលវេលា ប្រសិនបើអង្គជំនុំជម្រះសម្រេចថា វាមានភាពចាំបាច់ក្នុងការជំនួសមេធាវីបច្ចុប្បន្ន។ មេធាវីប្រចាំការមិនត្រូវចំណុះឱ្យក្រុមមេធាវីការពារក្តីបច្ចុប្បន្ននោះទេ។ មេធាវីប្រចាំការនឹងសិក្សាស្វែងយល់ភ្លាមៗលើសំណុំរឿង និងសេចក្តីសន្និដ្ឋានរបស់ភាគីនៅក្នុងសំណុំរឿង ០០២ ហើយពួកគេនឹងមិនពិគ្រោះយោបល់ ឬ ទទួលការណែនាំពីជនជាប់ចោទ ខៀវ សំផន នោះទេ លើកលែងតែមានការបង្គាប់ផ្សេងពីនេះដោយអង្គជំនុំជម្រះសាលាដំបូង។ មេធាវីប្រចាំការត្រូវចូលរួមគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់នៅក្នុងសំណុំរឿង ០០២/០២ ចាប់តាំងពីថ្ងៃតែងតាំងតទៅ។ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានភាពចាំបាច់ត្រូវបង្គាប់ឱ្យមេធាវីប្រចាំការជំនួសមេធាវីបច្ចុប្បន្នសម្រាប់ ខៀវ សំផន នោះ មេធាវីប្រចាំការត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

ក) ការពារឱ្យជនជាប់ចោទ ដោយត្រូវត្រៀមខ្លួនសម្រាប់ការផ្តល់សក្ខីកម្មរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ និងសួរដេញដោលអ្នកទាំងអស់នេះនៅក្នុងតុលាការ។

ខ) ធ្វើរាល់សេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ ដែលពួកគេយល់ឃើញថាសមស្រប ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះ។

គ) ស្នើសុំការសម្រេចពីអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីដែលពួកគេយល់ឃើញថា មានភាពចាំបាច់ ដើម្បីផ្តល់លទ្ធភាពដល់ពួកគេក្នុងការការពារជនជាប់ចោទឱ្យបានត្រឹមត្រូវ។

ឃ) ពិភាក្សាជាមួយនឹងជនជាប់ចោទអំពីការធ្វើចំណាត់ការលើរឿងក្តី ព្យាយាមទទួលការណែនាំពីជនជាប់ចោទ និងពិចារណាលើការយល់ឃើញរបស់ជនជាប់ចោទ ក្នុងពេលជាមួយគ្នានោះ ត្រូវរក្សាសិទ្ធិក្នុងការសម្រេចអំពីកិច្ចដែលនឹងត្រូវធ្វើឡើង និង

ង) គោរពតាមដីកាសម្រេចរបស់តុលាការ និងអនុវត្តតាមក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក រួមទាំង ច្បាប់ អ.វ.ត.ក កិច្ចព្រមព្រៀង អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្តនៃ

អ.វ.ត.ក និងសេចក្តីណែនាំរដ្ឋបាល ព្រមទាំងច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈនៃគណៈមេធាវី និងក្រមសីលធម៌វិជ្ជាជីវៈមេធាវីដែលត្រូវបានទទួលស្គាល់ផងដែរ។

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**ច្រានចោល** សំណើរបស់សហព្រះរាជអាជ្ញា សុំតែងតាំងមេធាវីដែល *ជាមិត្តរបស់តុលាការ*។

**បង្គាប់** ឱ្យអង្គភាពគាំពារការការពារក្តី តែងតាំងមេធាវីប្រចាំការអន្តរជាតិម្នាក់ និងជាតិម្នាក់សម្រាប់ ខៀវ សំផន ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងសម្រាប់រយៈពេលនៃសំណុំរឿង ០០២/០២។

**បង្គាប់** ឱ្យអង្គភាពគាំពារការការពារក្តីចាត់វិធានការណាមួយ និងវិធានការគ្រប់បែបយ៉ាងដើម្បីបំពេញមុខតំណែងថ្មីនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

**បង្គាប់បន្ថែមទៀត** ឱ្យអង្គភាពគាំពារការការពារក្តីរាយការណ៍ជូនអង្គជំនុំជម្រះជារៀងរាល់សប្តាហ៍អំពីវិធានការដែលខ្លួនបានធ្វើឡើងដើម្បីរក្សា និងធានាវត្តមានរបស់មេធាវីប្រចាំការដែលតែងតាំងដោយតុលាការ នៅក្នុងទីក្រុងភ្នំពេញដោយរបាយការណ៍លើកទីមួយត្រូវធ្វើឡើងនៅថ្ងៃសុក្រ ទី ១២ ខែ ធ្នូ ឆ្នាំ ២០១៤ ជាកំហិត។

**ស្នើសុំ** ឱ្យការិយាល័យរដ្ឋបាលផ្តល់ការគាំទ្រចាំបាច់គ្រប់បែបយ៉ាងដើម្បីជួយសម្រួលដល់ការបង្គាប់នៅក្នុងសេចក្តីសម្រេចនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

E.C.C.C * C.E.T.C * TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**